HONEYCOMB 2/2 (April 2001): 16–23



# How Can the Church Prevent the Breakdown of the Fragmenting Cambodian Family?

*Glenn MILES*

## What is a family?

The Cambodian view of the family differs from that of typical Western conservative Protestants. The latter have regarded the "nuclear" family—typically with three or four members—as the traditional model. But this view owes more to European culture than to the Bible, and is far from what is "normal" in most cultures, including Cambodia.

In Bible times Hebrew families were grouped together in houses. An interdependent Hebrew household was made up of between fifty and one hundred people. These were in turn united through marriage, kinship, and adoption to form clans. Several clans constituted a tribe, and the confederation of tribes made up Israel. According to this model, the family was not just a social unit but also an economic and political one. Marriages were arranged and a "bride price" paid to seal the covenant.[1] Whole households, including children, worked together on the land. This pattern has much in common with the extended families found in rural Cambodia today.

---

[1]Gen 34:1; 1 Sam 18:25; Lev 27.

In this context marriage is usually arranged, and a covenant is made not just between individuals, but also between families. Where parents are loving and concerned for their children's welfare, arranged marriages can result in a successful union of dynasties. They are also a strong reminder that two *families* are being brought together, not just two individuals. This can strengthen the bonds within the community, and economic ties further reinforce the relationship.

**What causes family breakdown in Cambodia?**

Problems may arise within this model if parents of a bride and groom make decisions for their children without any regard for their opinions or needs, such as choosing a partner on purely financial grounds. Another unhealthy model in Cambodia is the dominant patriarchal marriage, in which men become abusive towards their wives and children, and rarely if ever consult them in decisions that affect them. Domestic violence is common in Cambodia.

Political ideologies, too, sometimes wage war against the family unit. For example, during the Pol Pot era the family rice pot was broken as a symbol that the new regime would do away with the need for the family. Everything was supposed to be provided by the *Angkar* (the new regime), which even arranged marriages. Children were expected to speak out against their parents if they were going "against the *Angkar*." Many children became the soldiers who enforced the rules; such a role reversal violated the traditions of respect for the elders.

Cambodian culture still contains many fatalistic attitudes. Men still blame their wives if the family is poor, and feel that this can justify their desertion.

In a society where people's belief structures—in Cambodia's case Buddhism, animism, and communism—have been challenged and left a vacuum, people may turn to materialism as the answer. Money becomes a god. "If only I had enough money everything would be OK," people think. So in some "middle-class" families both parents work long and late, and see very little of their families or each other. Relationships become frail and break down.

**What is God's concern for families in Cambodian society?**

What would God have us promote or discourage, protect or challenge, in the area of family life? Scripture does not always present a rosy picture of the family. We read of fratricide, rape, incest, adultery, and murder—as well as love and loyalty—both within households and beyond them.

Nevertheless, the "family" can be a relationship and an institution in which God's grace is experienced and where people can find nurture and healing. It is a place where they can grow as persons in their individuality, in their social relations, and in their relationship with God.[2] However, like any special relationship and institution, "the family" can become perverted by sin, with people being disloyal, competing for power, and neglecting responsibilities. Sadly, some churches have at times misinterpreted Scripture in an attempt to justify such wrong behavior.

As mentioned earlier, the Old Testament gives us the model of the extended family. This was not just a social but also an economic and political unit. In the New Testament we see marriage as a covenant relationship, characterized by mutual submission, respect, and service. Thomas Aquinas[3] described how children are made in part in the image of their parents, and therefore naturally belong to and are valued by them. But they are also made in the image of God, and belong to and are valued by Him. He compares Christ's sacrificial love for his church in Ephesians 5 to a father's love, in order to reinforce the long-term commitment of fathers and husbands to their children and wives.

Yet the family in the New Testament is seen not just in terms of kinship and marriage, but also as the community of believers. Paul describes the church as a family. The New Testament church met in households, where fellow believers were to be welcomed like relatives. Those baptized, according to Paul,

---

[2]Stephen C. Barton, "Towards a Theology of the Family," *Crucible Board for Social Responsibility* (Jan–Mar 1993): 4–12.

[3]S. Pope, *The Evolution of Altruism and the Ordering of Love* (Washington, D.C.: Georgetown University, 1994).

have been adopted by God.[4] Their siblings are other Christians. Their inheritance is the community of believers.[5]

In a culture where the family was more important than all other relationships, the New Testament church was to reach out to the Gentiles, to the unlovely, and even to enemies. Clapp suggests, "Paradoxically, a family is enriched when it is de-centred."[6] The Christian family is therefore not a safe haven from the world, but rather a powerful witness to the world. Even vulnerable families need to learn the responsibility and joy of reaching out in hospitality, rather than fearfully withdrawing into a "bunker" type of self-preservation mentality, which has been so common in the Cambodian environment of thirty years of war.

Jesus himself reinforced the importance of the community of believers on various occasions. He emphasized his relationship with his heavenly Father over his parents,[7] and he described the disciples as his "mother and brothers" over his own family.[8] Later he says that those who love father or mother more than they love him are not worthy of him.[9]

This is not to denigrate the family. In a country where the father of many children is absent because of Pol Pot, civil war, abandonment, HIV/AIDS, or simply excessive work demands, we need to encourage men to take their responsibility for their wives and children seriously. God sent angels to ensure that Joseph took his responsibility in fathering Jesus seriously and did not abandon Mary as he might have done. God went to some trouble to make sure there was no risk of the breakdown of the marriage of Joseph and Mary, thus ensuring that there were two parents.

---

[4]Rom 8:15–17, Gal 3:26–4:6.

[5]Mark 10:28–31.

[6]Ronald Clapp, *Families at the Crossroads: Beyond Traditional Roles and Modern Options* (Downers Grove: Intervarsity, 1993).

[7]Luke 2:41–52.

[8]Mark 3:34–35.

[9]Matt 10:37.

## How can the church support the family?

Parenting in Scripture occurs in the context of marriage. This does not mean that in ministry we ignore those who are parenting outside a marriage, but it does mean that we value the relationship between parenting and marriage within the church. The church also needs to find ways to stop men from drifting away from families and parenthood. Cambodian men need to understand that if their families are poor it is not their wives' fault. There is no room for fatalism in the church, and the church needs to challenge such assumptions. Cambodian men also must understand the importance of faithfulness to their wives and families, and avoid promiscuity.

Supporting parents is vital. There needs to be encouragement of *parental responsibilities* towards children and the development of a *caring community* around them. "God himself trusted His own Son to humankind as a vulnerable child, requiring that Son to be nurtured by a frail but able family and community, symbolically provid[ing] a model of trust and responsibility. . . ."[10]

In the Old Testament, although children were entirely subject to the authority of the head of the household and counted legally as his property, "there was much greater concern with the *responsibility* of the father for his children than with his *rights* over them."[11] The *shema*, the Hebrew confession of faith, was to be impressed on children "when you sit at home, when you walk along the road, when you lie down and when you get up." Parental responsibility to teach children the truth about God and godly living was vital. In Proverbs 6:20 children are encouraged to keep their father's commands and not to forsake their mother's teaching. Proverbs 22:6 talks about the responsibility of parents to create a

---

[10]Viva Network, "The Oxford Statement" (Oxford: Oxford Centre for Mission Studies, and Viva Network, Jan 6–10, 1997).

[11]Chris J. W. Wright, *God's People in God's Land* (Cumbria, U.K.: Paternoster, 1997), 239. See Deut 21:18–21; 21:16; 2 Ki 14:5–6.

desire for spiritual things in children from a young age.[12] Men in the church can and should provide role models for children.

In the early church children were encouraged to obey their parents. There is no surprise about this. It reflects one of the Ten Commandments Moses received. However, parents were then encouraged to "bring children up in the discipline and instruction of the Lord," and fathers were encouraged not to "exasperate your children, lest they lose heart."[13] Since Paul's letters were to be read aloud to the whole churches to which they were sent, the fact that he addressed parents *and* children in them is significant. First, he assumes that children belong to the community of the church and that they would be present when his letters were read. Second, he encourages *mutual* responsibilities on parents and children. This challenges the common assumption at that time that the parental role carried with it unlimited authority over the children of the family.

Although parenting does require sacrifice, "loving your neighbor as yourself" is key.[14] "Love as equal regard" provides a balance between modern individualism and the more traditional ethics of extreme duty and self-sacrifice. This understanding of love is especially important for those Cambodian mothers and wives who have "disproportionately carried the burden of enacting self-sacrificial models of Christian love."

While children can most benefit from growing up in a two-parent family, this is not always possible. Both the Old and New Testaments mention responsibility to orphans and the fatherless. Being an orphan in ancient times meant being deprived of support, losing legal standing, and becoming vulnerable to those who would exploit the weak. God is seen as the defender of the fatherless,[15] and the covenant community is encouraged to practice similar

---

[12]Deut 6:4-9.

[13]Eph 6:1–4; Col 3:21.

[14]Don Browning, "Christian Ethics and the Family Debate: An Overview," virtual *International Journal of Practical Theology*: 1999 [www2.uchicago.edu/divinity/family/].

[15]Deut 10:18.

compassion.[16] The same was true of the early church, where a "pure and faultless" religion was exemplified by those who "look after orphans and widows."[17]

The difficulty for the Cambodian church today is that there are many children who do not fit neatly into the two-parent family structure. Children may have been separated from one or both parents through war, disaster, accident, or the ill health of a parent. In the past there have been culturally appropriate ways of absorbing orphans—into the extended family or into a monastery, for example. However some communities—for example those greatly affected by war or those with a high incidence of HIV/AIDS—may feel they cannot cope. In these situations the supportive environment of the church family can provide a model different from that of the surrounding community and explore how it can support orphans

The Cambodian church has many families headed by women. Pastors need to understand how each situation arose, because the issues such families face will vary according to the circumstances. One family may suffer a history of violence and abuse, whereas others may have to deal with widowhood, desertion, or promiscuity. There are no simplistic solutions. The church must first find out what the needs are by gently developing relationships, asking, and then being ready with appropriate support.

Grandparents, aunts, and uncles, where available, can play a supportive role. This should be encouraged. In some cases they are the main providers of care for the child. The influence of peers is also important for children's physical, emotional, and spiritual development.

Cambodian churches need to recognize that the number of orphans is likely to increase due to HIV/AIDS, and must take the issue of orphans seriously. One Takhmao church with a congregation of eighty has taken on the responsibility for seventeen orphans. Various members have opened their homes to children to sleep overnight, and then part of the collection money on Sunday

---

[16]Ex 22:27.

[17]Jas 1:27.

goes towards paying for their food. They are taking the Biblical mandate of caring for widows and orphans seriously.

As well as considering what to do with orphans in the community, the church needs to look at how they can prevent children from being orphaned in the first place. In Cambodia this may result from loss of parents by death or abandonment, but children can receive inadequate care for other reasons. Where a marriage is fragile, the church needs to support and strengthen the marriage. In this way it may enable relationships to be restored and prevent family breakdown, violence against women, desertion, and divorce. Similarly where parent–child relationships are strained, support of parents in a loving community may prevent child abuse and inter-generational violence. There may be other ways that the church can temporarily look after children until vulnerable parents can develop greater resilience.

The church in Cambodia can provide a model very different from that of the surrounding community. Ideally, Christian couples are committed to each other and to their children, and are secure enough in God's love that they are willing to reach out to the unlovely and include them as part of their extended family.

---

A modified version of this article was presented to the United Pastors Fellowship Annual Retreat on 8 March 2001 at Kompong Som.

សំណុំនិគឃ្មុំ ២/២ (មេសា ២០០១): ២៤-៣៧



# តើពួកជំនុំអាចជួយការពារការបាក់បែក នៃគ្រួសារខ្មែរបានដោយរបៀបណា?

ហ្គលិន ម៉ៃយល៍

## អ្វីទៅដែលហៅថាគ្រួសារ?

ទស្សនៈរបស់ខ្មែរ ស្ដីពីគ្រួសារមានលក្ខណៈខុសប្លែក ពីលក្ខណៈនៃពួកជំនុំប្រូតេស្តង់អភិរក្សនៅលោកខាងលិច ។ គ្រួសារនៅលោកខាងលិចនេះបានចាត់ទុកថា "គ្រួសារតូច" ដែលជាទូទៅមានសមាជិកគ្រួសារតែបីឬបួននាក់តែប៉ុណ្ណោះ ថាជាគ្រួសារគំរូតាមប្រពៃណីបស្ចិមប្រទេស ។ ប៉ុន្តែទស្សនៈបែបនេះ មានទំនោរទៅរកវប្បធម៌អឺរ៉ុបច្រើនជាងព្រះគម្ពីរ ហើយក៏ខុសពីលក្ខណៈធម្មតា"នៅក្នុងវប្បធម៌ភាគច្រើនដែលរាប់បញ្ចូលទាំងទំនៀមទម្លាប់វប្បធម៌ នៅក្នុងប្រទេសខ្មែរផងដែរ ។

កាលពីសម័យ ដែលគេសរសេរព្រះគម្ពីរ គ្រួសាររបស់ពួកហេប្រឺរស់នៅផ្ដុំគ្នាជាក្រុម នៅក្នុងគេហដ្ឋាន ។ ក្រុមគ្រួសារហេប្រឺ ដែលមានការពឹងពាក់ពំនាក់អាស្រ័យដល់គ្នាទៅវិញទៅមក មានគ្នាចាប់ពី ៥០ ទៅដល់

១០០ នាក់ ។ ការនេះកើតឡើង ដោយសារការភ្ជាប់សាច់ឈាម តាមរយៈការរៀបអាពាហ៍ពិពាហ៍ ការជាប់ជាសាច់ញាតិ និង ការរាប់ជាកូនចិញ្ចឹមដើម្បីបង្កើតឡើងជាអំបូរ ។ អំបូរជាច្រើនបានបង្កើតឡើងជាកុលសម្ព័ន្ធ និង កុលសម្ព័ន្ធរួមគ្នាច្រើន បង្កើតឡើងបានជាប្រទេសអ៊ីស្រាអែល ។ យោងតាមគំរូនេះឯង គ្រួសារមិនគ្រាន់តែជាផ្នែកតូចមួយរបស់សង្គមប៉ុណ្ណោះទេ តែជាផ្នែកមួយ ដែលទាក់ទងដល់សេដ្ឋកិច្ច និង នយោបាយទៀតផង ។

ឪពុកម្តាយគឺជាអ្នករៀបចំអាពាហ៍ពិពាហ៍ឲ្យកូន "ថ្លៃបណ្ណាការឬថ្លៃកូនក្រមុំ" ភាគីខាងប្រុសជាអ្នកបង់ ដើម្បីផ្សារភ្ជាប់នូវចំណង មេត្រី ។[១] គ្រួសារទាំងមូលរួមទាំងកូនចៅ ធ្វើការជាមួយគ្នានៅក្នុងស្រែចំការ ។ គំរូបែបនេះ យើងឃើញមានជាធម្មតានៅក្នុងគ្រួសារខ្មែរ ដែលនៅតាមជនបទដាច់ស្រយាលនៅសម័យសព្វថ្ងៃនេះ ។

ក្នុងស្ថានការណ៍បែបនេះអាពាហ៍ពិពាហ៍និងការចងស្ពានមេត្រីត្រូវបានគេរៀបចំឡើង ដើម្បីផ្សារភ្ជាប់កូនកម្លោះជាមួយនឹងកូនក្រមុំ និង គ្រួសារខាងប្រុសជាមួយនឹងគ្រួសារខាងស្រី។ ឪពុកម្តាយដែលស្រឡាញ់ និងខ្វល់ខ្វាយពីសុខមាលភាពរបស់កូនខ្លួនរៀបចំអាពាហ៍ពិពាហ៍ ឲ្យកូនប្រកបដោយភាពជិតស្និទ្ធ និងប្រកបដោយជោគជ័យនៃពូជពង្សវង្សត្រកូលល្អ ។ គេក៏បាននឹកចាំយ៉ាងច្បាស់ថា គ្រួសារពីរបានភ្ជាប់និស្ស័យជាមួយគ្នា គឺមិនមែនគ្រាន់តែភ្ជាប់និស្ស័យតែមនុស្សពីរនាក់នោះឡើយ ។ ការនេះអាចជួយពង្រឹងចំណងជាមួយសហគមន៍ផង ហើយចំណងសេដ្ឋកិច្ច ក៏ជួយពង្រឹងទំនាក់ទំនងឲ្យកាន់តែរឹងមាំឡើង ។

---

(១) *លោកុប្បត្តិ(កំណើតពិភពលោក) ៣៤:១; ១សាមូអែល ១៨:២៥; លេវីវិន័យ ២៧*

## តើមូលហេតុអ្វីនាំឲ្យគ្រួសារបាក់បែកនៅក្នុងប្រទេសកម្ពុជា?

បញ្ហាជាច្រើនអាចនឹងកើតមានឡើង នៅក្នុងគំរូនេះ បើឪពុកម្ដាយរបស់កូនក្រមុំ និង កូនកម្លោះ សម្រេចចិត្តជំនួសកូនរបស់ខ្លួន ដោយ មិនរាប់រកដល់គំនិត ឬ សេចក្ដីត្រូវការរបស់កូន ដូចជាការជ្រើសគូស្រករឲ្យកូន ដោយផ្ដោតសំខាន់លើទ្រព្យសម្បត្តិ ។ គំរូមិនល្អមួយទៀតនៅក្នុងប្រទេស កម្ពុជា គឺអាពាហ៍ពិពាហ៍បែប "បិតុធិបតេយ្យ" ដែលបុរសមានអំណាចលើប្រពន្ធកូនខ្លួន និង កម្រមានបុរសណាមកសួរយោបល់ពីប្រពន្ធកូន នៅក្នុងពេលសម្រេចចិត្តលើកិច្ចការអ្វីមួយ ដែលមានឥទ្ធិពលប៉ះពាល់ដល់ពួកគេទាំងអស់គ្នានោះ ។ អំពើហឹង្សានៅក្នុងគ្រួសារក្លាយជារឿងធម្មតាទៅហើយ នៅក្នុងប្រទេសកម្ពុជា ។

មនោគមវិជ្ជាផ្នែកនយោបាយ ជួនកាលក៏នាំឲ្យមានសង្គ្រាមប្រឆាំងនឹងគ្រួសារដែរ ។ ឧទាហរណ៍នៅសម័យ ប៉ុល ពត គេបង្កើតរបបមួយដែលបំបែកឆ្នាំងបាយគ្រួសារចោល ដោយប្រើឆ្នាំងបាយរួមជំនួសវិញ ជានិមិត្តរូបនៃការបង្កើតរបបថ្មីមួយ ដែលផាត់ចោលសេចក្ដីត្រូវការរបស់ក្រុមគ្រួសារ ។ របស់គ្រប់យ៉ាងទាំងអស់ត្រូវ*អង្គការ* (របបថ្មី) ផ្ដល់ឲ្យដែរ សូម្បីតែការរៀបចំអាពាហ៍ពិពាហ៍ ក៏ត្រូវ*អង្គការ*ជាអ្នករៀបចំឲ្យដែរ ។ គេតម្រូវឲ្យកូនៗនិយាយប្រឆាំងនឹងឪពុកម្ដាយរបស់ខ្លួន បើសិនជាឪពុកម្ដាយនោះហ៊ានធ្វើអ្វី ដែលប្រឆាំងជាមួយ*អង្គការ* ។ ក្មេងៗជាច្រើនធ្វើជាឈ្លបឬទាហាន ដែលជួយគាំទ្រដល់ការកាន់អំណាចគ្រប់គ្រងបែបនោះ។ ការប្រព្រឹត្តិបែបនោះ គឺធ្វើផ្ទុយ ហើយបង្ខូចដល់ទំនៀមទម្លាប់ខ្មែរដែលគោរពរាប់អានដល់មនុស្សចាស់ៗនោះ ។

ទំនៀមទម្លាប់របស់ខ្មែរ ច្រើនតែជាប់ជិតដាមនូវអ្វីដែលមានឥរិយាបថជឿលើព្រេងសំណាងហួសហេតុ ។ ទស្សនៈ "សំណាបយោងដី ស្រីយោងប្រុស" លើកទឹកចិត្តបុរសឲ្យបន្ទោសប្រពន្ធ ថាជាមូលហេតុ

បណ្តាលឲ្យគ្រួសារធ្លាក់ខ្លួនក្រ ហើយបុរសក៏យកហេតុផលនេះឯង មក លែងលះភរិយាកញ្ឆើផ្ទះរបស់ខ្លួន ។

នៅក្នុងសង្គមណាមួយដែលមានប្រព័ន្ធជំនឿដូចជាករណីប្រទេស កម្ពុជាដែលកាន់លទ្ធិពុទ្ធនិយម អារុក្ខអារក្សអ្នកតានិយម និងកុម្មុយនីស្ត និយមនោះតែងមានបញ្ហា និងបន្សល់ទុកនូវភាពប្រហោងធ្លុងហោងហាង ក្នុងចិត្ត ។ មនុស្សដែលបានឆ្លងកាត់ហេតុការណ៍ខាងលើនេះ អាចវិល បែរទៅឈោងចាប់យកសម្ភារៈនិយម ទុកជាចម្លើយសម្រាប់បំពេញភាព ហោងហាងនៅក្នុងជីវិត ។ លុយក្លាយជាព្រះ មនុស្សភាគច្រើនតែងគិត ថា "បើសិនជាអញមានលុយគ្រប់គ្រាន់ អ្វីៗគ្រប់យ៉ាងនឹងមានដំណើរការ ល្អ" ។ ដូច្នេះហើយ នៅក្នុងគ្រួសារ"ថ្នាក់កណ្តាល"ខ្លះ ឪពុកម្តាយខំធ្វើការ យ៉ាងយូរ ចំណាយពេលរកស៊ីច្រើនពេក រហូតមានពេលតិចតួចណាស់ សម្រាប់គ្រួសារ ឬ ការជួបមុខគ្នា ។ ទំនាក់ទំនងក្នុងគ្រួសារ ក៏ចាប់ផ្តើម ប្រេះស្រាំ និង បាក់បែកទៅ ។

## តើព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ចំពោះជីវិត គ្រួសារក្នុងសង្គមខ្មែរដោយរបៀបណា?

តើព្រះជាម្ចាស់ ឲ្យយើងគាំទ្រការពារ ឬ ជំរុញឲ្យមានការលើកទឹក ចិត្តដល់ជីវិតគ្រួសារ ។ បទគម្ពីរមិនបានបង្ហាញរូបភាពស្រស់បំព្រងនៃ គ្រួសារនោះឡើយ ។ យើងបានអានរបាយការណ៍ស្តីអំពីការសម្លាប់បង ប្អូនឯង ការចាប់រំលោភ អំពើសាហាយស្មន់ កំផិត និង ការកាប់សម្លាប់ ដូចគ្នានេះដែរ ការមានសេចក្តីស្រឡាញ់ និង ភាពស្មោះត្រង់ នៅក្នុង គ្រួសារ និង ហួសពីការប្រព្រឹត្តិទាំងនោះ ។

ទោះបីជាយ៉ាងណាក៏ដោយ "គ្រួសារ" អាចជាទំនាក់ទំនងមួយ និង អាចជាស្ថាប័នមួយ ដែលគេអាចទទួលនូវបទពិសោធន៍នៃព្រះគុណព្រះជាម្ចាស់ និង ជាកន្លែងដែលមនុស្សអាចប្រទះឃើញនូវការចាស់ចិត្តចាស់គំនិត និង ការជាសះស្បើយពីការឈឺចាប់ផ្សេងៗ ។ គ្រួសារគឺ ជាកន្លែង ដែលគេអាចចំរើនលូតលាស់ ក្នុងលក្ខណៈជាបុគ្គល ក្នុងទំនាក់ទំនងផ្នែកសង្គម និង ទំនាក់ទំនងជាមួយព្រះជាម្ចាស់[២] ។ ទោះជាអ៊ីចឹងក្តី គ្រួសារក៏ដូចជាទំនាក់ទំនងពិសេស ឬ ស្ថាប័នដទៃទៀតដែរ អាចទទួលរងការបំផ្លាញដោយអំពើបាប ចិត្តវៀចវេរ ការប្រជែងដណ្តើមអំណាចគ្នា និង ការខ្វះភាពទទួលខុសត្រូវ ។ គួរឲ្យស្តាយណាស់ ពួកជំនុំខ្លះមានពេលខ្លះបកស្រាយបទគម្ពីរខុស ដោយព្រោះមានគោលបំណងដើម្បីរកលេសដោះស្រាយ និង គាំទ្រការប្រព្រឹត្តិខុសឆ្គងបែបនោះឯង ។

ដូចដែលបានលើកមកជំរាបខាងដើមរួចហើយ ព្រះគម្ពីរសញ្ញាចាស់ បានផ្តល់ឲ្យយើងនូវគំរូនៃគ្រួសារធំរស់នៅជាចង្កោមញាតិសន្តាន ។ ការរស់នៅបែបនេះ មិនគ្រាន់តែការរស់នៅជាសង្គមគ្រួសារ ប៉ុណ្ណោះទេ តែជាការរស់នៅ ដោយសំអាងលើកត្តាសេដ្ឋកិច្ចនិងកត្តានយោបាយទៀតផងដែរ ។ នៅក្នុងគម្ពីរសញ្ញាថ្មីយើងឃើញថាអាពាហ៍ពិពាហ៍ គឺជាការផ្សារភ្ជាប់នូវទំនាក់ទំនង ដែលបង្ហាញពីចរិតលក្ខណៈដោយការចុះចូលគ្នាទៅវិញទៅមក ការគោរពគ្នាទៅវិញទៅមក និងដោយការបំរើគ្នាទៅវិញទៅមក ។ លោកថូម៉ាស់ អាគីណាស[៣]បានពណ៌នាពីការដែលកូនៗបានកើតមកក្នុងផ្ទៃកខ្លះ ដែលមានលក្ខណៈកាត់ទៅរកឪពុកម្តាយរបស់គេ និង ហេតុដូច្នេះហើយតាមលក្ខណៈធម្មជាតិកូនៗទាំងនោះ គឺជាកម្មសិទ្ធិ

---

[២] Stephen C. Barton, "Towards a Theology of the Family," *Crucible Board for Social Responsibility* (Jan–Mar 1993): 4–12.

[៣] S. Pope, *The Evolution of Altruism and the Ordering of Love* (Washington, D.C.: Georgetown University, 1994).

និង ជារបស់មានតម្លៃបំផុតចំពោះឪពុកម្តាយ ។ ប៉ុន្តែមិនគ្រាន់តែកូនៗទាំងអស់ មានរូបរាងកាត់ដូចឪពុកម្តាយរបស់គេប៉ុណ្ណោះទេ គឺកូនៗទាំងនោះកើតមកជារូបឆ្លុះរបស់ព្រះជាម្ចាស់ទៀតផង និងជាកម្មសិទ្ធិរបស់ព្រះព្រមទាំងព្រះអង្គឲ្យតម្លៃលើគេយ៉ាងខ្លាំងទៀតផងដែរ ។ លោក ថូម៉ាស់ ប្រៀបធៀបសេចក្តីស្រឡាញ់ ដែលព្រះគ្រីស្តព្រមលះបង់សម្រាប់ពួកជំនុំរបស់ព្រះអង្គ នៅក្នុងអេភេសូ ជំពូក ៥ ទៅនឹងសេចក្តីស្រឡាញ់របស់ឪពុក ។ គាត់លើកចំណុចនេះដើម្បីពង្រឹង នូវការប្តូរផ្តាច់យ៉ាងយូរអង្វែងរបស់ឪពុក និង ប្តី ក្នុងការស្រឡាញ់កូន និង ប្រពន្ធរបស់គេ ។

ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងគម្ពីរសញ្ញាថ្មី យើងឃើញថាមិនគ្រាន់តែជាចំណងនិស្ស័យក្នុងគ្រួសារញាតិសន្តាន និង ក្នុងអាពាហ៍ពិពាហ៍ប៉ុណ្ណោះទេ ប៉ុន្តែជាសហគមន៍មួយនៃក្រុមអ្នកជឿ ។ លោក ប៉ូលពណ៌នាអំពីពួកជំនុំទុកដូចជាគ្រួសារ ។ ក្រុមជំនុំនៅក្នុងសម័យព្រះគម្ពីរសញ្ញាថ្មី ជួបប្រជុំគ្នានៅតាមផ្ទះសម្បែង ហើយសមាជិកក្រុមជំនុំទាំងនោះ ត្រូវបានគេទទួលនូវការស្វាគមន៍ដូចជាសាច់ញាតិដែរ ។ យោងតាមសេចក្តីបង្រៀនរបស់លោក ប៉ូល អ្នកណាដែលបានទទួលពិធីជ្រមុជទឹក អ្នកនោះក្លាយទៅជា កូនចិញ្ចឹមរបស់ព្រះជាម្ចាស់ហើយ[៤] ។ គឺគេមានគ្រីស្តបរិស័ទដទៃទៀតជាបងប្អូន ។ មត៌ករបស់គេគឺជាសហគមន៍នៃពួកអ្នកជឿ[៥] ។

នៅក្នុងទំនៀមទម្លាប់មួយ ដែលគេគិតថាគ្រួសារសំខាន់ជាងទំនាក់ទំនងដទៃទៀតនោះ ក្រុមជំនុំក្នុងសម័យព្រះគម្ពីរសញ្ញាថ្មីបង្រៀនឲ្យឈោងចាប់ដល់អ្នកក្រៅត្រកូល (ជាសាសន៍ដទៃ) ដល់អ្នកដែលគួរឲ្យស្រឡាញ់រាប់អាន និង សូម្បីតែខ្មាំងសត្រូវក៏ត្រូវបានគេរាប់អានដែរ ។

---

[៤] រ៉ូម ៨:១៥-១៧, កាឡាទី ៣:២៦-៤:៦ ។

[៥] ម៉ាកុស ១០:២៨-៣១ ។

លោក ក្លែប បានផ្ដល់នូវការណែនាំថា "ជួយស្រឡះពីអ្វីៗផ្សេងឯទៀត គ្រួសារមានភាពសំបូរសប្បាយជាងមុន កាលណាគ្រួសារនោះបំបែកជាក្រុមតូចៗ"[៦] ។ ហេតុដូច្នេះហើយ បានជាគ្រួសារគ្រីស្ទបរិស័ទ មិនមែនជាកន្លែង ដែលសម្ងំសុខ មិនអើពើពីលោកិយនោះឡើយ ប៉ុន្តែជាកន្លែងមួយ ដែលបង្ហាញពីអំណាចចេស្ដា ក្នុងការធ្វើបន្ទាល់ដល់លោកិយទៅវិញទេ ។ ទោះបីជាគ្រួសារគ្រីស្ទបរិស័ទលំបាកតោកយ៉ាក ក៏ត្រូវដឹងពីភាពទទួលខុសត្រូវ និង អំណាចនៃការឈោងចាប់លោកិយ ដោយបង្ហាញពីភាពរាក់ទាក់ ទទួលយ៉ាងកក់ក្ដៅជាជាងការបង្ហាញពីភាពភ័យខ្លាច រួញខ្លួនលាក់ខ្លួនក្នុង "លេណដ្ឋាន" ព្រោះមានគំនិតចង់បានសេចក្ដីសុខផ្ទាល់ខ្លួន ដែលនេះជារឿងធម្មតានៅក្នុងស្ថានការណ៍នៃសង្គ្រាម ៣០ ឆ្នាំនៃប្រទេសកម្ពុជា ។

ព្រះយេស៊ូផ្ទាល់ បានផ្ដល់ការគាំទ្រលើសារៈសំខាន់នៃសហគមន៍នៃពួកអ្នកជឿនៅក្នុងឱកាសផ្សេងៗជាច្រើន ។ ព្រះអង្គបានសង្កត់ធ្ងន់ពីទំនាក់ទំនងរបស់ព្រះអង្គជាមួយព្រះបិតារបស់ព្រះអង្គ ដែលនៅឯស្ថានសួគ៌ប្រាប់ដល់ឪពុកម្ដាយរបស់ព្រះអង្គ[៧] ហើយព្រះអង្គពណ៌នា ពីពួកសិស្សទុកដូចជា "ម្ដាយ និង បងប្អូន" របស់ព្រះអង្គ ដោយសង្កត់បន្ថែមថា ជាគ្រួសាររបស់ព្រះអង្គផ្ទាល់[៨] ។ ក្រោយមកទៀត ព្រះអង្គមានបន្ទូលថា អស់អ្នកណាដែលស្រឡាញ់ឪពុក ឬ ម្ដាយ ច្រើនជាងព្រះយេស៊ូនោះ មិនសមជាសិស្សព្រះអង្គឡើយ[៩] ។

---

[៦] Ronald Clapp, *Families at the Crossroads: Beyond Traditional Roles and Modern Options* (Downers Grove: Intervarsity, 1993).

[៧] *លូកា ២:៤១-៥២ ។*

[៨] *ម៉ាកុស ៣:៣៤-៣៥ ។*

[៩] *ម៉ាថាយ ១០:៣៧ ។*

ការនេះមិនមែនបានន័យថា គ្រួសារមិនមានសារៈសំខាន់នោះទេ ។ នៅក្នុងប្រទេសមួយ ដែលឪពុកនៃគ្រួសារមួយ ដែលមានកូនច្រើន បានបាត់បង់ជីវិតទៅ ដោយព្រោះតែរបប ប៉ុល ពត សង្គ្រាមស៊ីវិល (សង្គ្រាមក្នុងស្រុក) ការបោះបង់ចោលគ្រួសារ ព្រោះការលែងលះ ស្លាប់ចោលគ្រួសារ ដោយសារជម្ងឺអេដស៍ ឬ ដោយការធ្វើការងារច្រើនហួស បង្ខំឲ្យបែកពីគ្រួសារ យើងត្រូវលើកទឹកចិត្តដល់បុរសៗ ឲ្យទទួលខុសត្រូវដល់ប្រពន្ធ និង កូនរបស់គេ ដោយយកចិត្តទុកដាក់ជាទីបំផុត ។ ព្រះជាម្ចាស់បានចាត់ទេវទូតមកធានាអះអាងប្រាប់យ៉ូសែប ឲ្យទទួលខុសត្រូវ ក្នុងការធ្វើជាឪពុកចិញ្ចឹមរបស់ព្រះយេស៊ូ ដោយយកចិត្តទុកដាក់យ៉ាងខ្លាំង និងមិនត្រូវបោះបង់នាង ម៉ារា ដូចដែលគាត់បានគិត នឹងធ្វើនោះឡើយ ។ ព្រះជាម្ចាស់បានដោះស្រាយនូវបញ្ហាខ្លះ ដើម្បីឲ្យបានដឹងប្រាកដថា គ្មានបញ្ហាគ្រោះថ្នាក់ដល់ការបាក់បែកនៃចំណងអាពាហ៍ពិពាហ៍រវាង យ៉ូសែប និងម៉ារានោះឡើយ ហេតុដូច្នេះហើយទើបមានការធានាអះអាងយ៉ាងច្បាស់ថាត្រូវមានអ្នកបីបាច់ថែរក្សាពីរនាក់ (គឺឪពុក និង ម្តាយ) ។

## តើក្រុមជំនុំអាចគាំទ្រដល់គ្រួសារបានដោយរបៀបណា?

ការបីបាច់ថែរក្សាកូនក្មេងក្នុងឋានៈជា ឪពុកម្តាយ នៅក្នុងបទគម្ពីរបានលើកឡើង នៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍ ។ ការនេះមិនមែនបានន័យថា នៅក្នុងព័ន្ធកិច្ចបំរើព្រះ យើងមិនរាប់រកដល់អ្នកទាំងឡាយដែលមានការបីបាច់ថែទាំកូន ដោយមិនបានរៀបការនោះឡើយ ប៉ុន្តែគឺមានន័យថា យើងឲ្យតម្លៃលើទំនាក់ទំនងរវាងការបីបាច់ថែរក្សាកូន និងអាពាហ៍ពិពាហ៍នៅក្នុងក្រុមជំនុំ ។ ក្រុមជំនុំក៏ត្រូវស្វែងរកមធ្យោបាយដើម្បីបញ្ឈប់បុរសរាល់គ្នា ពីការបែកឆ្ងាយពីគ្រួសារ និង បែកចេញពីឋានៈជាអ្នកថែទាំកូននោះ ។ បុរសខ្មែរត្រូវយល់ថា គ្រួសាររបស់គេ ដែល

ធ្លាក់ខ្លួនក្រក្រីមិនមែនចង្រៃមកពីប្រពន្ធរបស់គេនោះឡើយ ។ ចូរកុំឲ្យមានការជឿព្រេងសំណាង កើតមានឡើងនៅក្នុងក្រុមជំនុំឡើយ ។ បុរសខ្មែរត្រូវយល់នូវសារៈសំខាន់ នៃភាពស្មោះត្រង់ ចំពោះប្រពន្ធរបស់ខ្លួន និងគ្រួសាររបស់ខ្លួន និង ជៀសវាងការចេញដើររកស្រីផ្សេង ។

ការជួយគាំទ្រក្នុងការបីបាច់ថែទាំកូន គឺមានសារៈសំខាន់អស្ចារ្យ ។ ត្រូវមានការផ្តល់លើកទឹកចិត្ត ដល់កូនចំពោះភាពទទួលខុសត្រូវជាឪពុកម្តាយ និង ផ្តល់ផ្នែកពង្រឹងឲ្យមានសហគមន៍ ដែលចេះជួយយកអាសាគ្នានៅជុំវិញកូនៗនោះឯង ។ "ព្រះជាម្ចាស់ផ្ទាល់បានប្រគល់ព្រះរាជបុត្រាព្រះអង្គផ្ទាល់ មកឲ្យមនុស្សជាតិក្នុងឋានៈជាកូនទុគត៌ម្នាក់ដែលតម្រូវឲ្យព្រះរាជបុត្រានោះ ទទួលនូវការបីបាច់ថែបំប៉ន ដោយសារអ្នកទន់ខ្សោយដែលមានសមត្ថភាព គឺបង្ហាញពីការផ្តល់ជាគំរូនៃការទុកចិត្ត និង ការទទួលខុសត្រូវ . . ."(១០) ។

នៅក្នុងគម្ពីរសញ្ញាចាស់ ទោះបីជាយ៉ាងណាក៏ដោយ កូនៗត្រូវចុះចូលទាំងស្រុងនឹងសិទ្ធិអំណាច នៃមេគ្រួសារ ហើយនិងគេត្រូវបានរាប់ទុកជារបស់ស្របតាមច្បាប់នៃមេគ្រួសារនោះ "មានការខ្វល់ខ្វាយយ៉ាងធំសម្បើមទាក់ទង នឹងការទទួលខុសត្រូវរបស់ឪពុកចំពោះកូនរបស់ខ្លួនជាជាងការទាក់ទងជាមួយនឹងសិទ្ធិរបស់ឪពុក ពីលើការគ្រប់គ្រងលើកូនចៅ"(១១) ។ ពាក្យ "សេម៉ា" ជាភាសាហេប្រឺ ការប្រកាសជំនឿ គឺគេសង្កត់ធ្ងន់ចំពោះកូនៗ "ពេលដេក ដើរ ឈរ អង្គុយ ពេលងើប ពេលក្រោក" ។ ឪពុកម្តាយត្រូវទទួលខុសត្រូវ ក្នុងការបង្រៀនកូនឲ្យស្គាល់ ពីសេចក្តីពិតនៃព្រះជាម្ចាស់ និង ការរស់នៅដោយកោតខ្លាចព្រះនោះគឺជាការសំខាន់ ។

---

(១០) Viva Network, "The Oxford Statement" (Oxford: Oxford Centre for Mission Studies, and Viva Network, Jan 6–10, 1997).

(១១) Chris J. W. Wright, *God's People in God's Land* (Cumbria, U.K.: Paternoster, 1997), 239. See Deut 21:18–21; 21:16; 2 Ki 14:5–6.

គម្ពីរសុភាសិត ៦:២០ បានលើកទឹកចិត្តឲ្យកូនរក្សាទុកនូវពាក្យបង្គាប់របស់ឪពុក និង ចាំទុកសេចក្តីបង្រៀនរបស់ម្តាយ ។ សុភាសិត ២២:៦ ចែងពីការទទួលខុសត្រូវរបស់ឪពុកម្តាយ ក្នុងការបង្កើតឲ្យមានភាពឆេះឆួលផ្នែកខាងវិញ្ញាណ នៅក្នុងជីវិតរស់នៅរបស់កូន តាំងពីគេនៅក្មេងនៅឡើយ[១២] ។ បុរសរាល់គ្នា ដែលនៅក្នុងក្រុមជំនុំ គួរផ្តល់នូវតួនាទីជាគំរូដល់កូនក្មេងទាំងឡាយ ។

នៅក្នុងក្រុមជំនុំជំនាន់ដើម គេលើកទឹកចិត្តឲ្យក្មេងៗស្តាប់បង្គាប់ឪពុកម្តាយរបស់គេ ។ គ្មានរឿងអ្វីដែលចម្លែកចំពោះរឿងនេះទេ ។ ការនេះ ធ្វើឲ្យយើងនឹកគិតទៅដល់បញ្ញត្តិមួយ នៅក្នុងបញ្ញត្តិទាំងដប់ប្រការរបស់លោក ម៉ូសេ បានទទួលពីព្រះជាម្ចាស់ ។ ទោះបីជាយ៉ាងណាក៏ដោយឪពុកម្តាយត្រូវលើកទឹកចិត្តឲ្យ "ប្រដៅតម្រង់កូន និង បង្រៀនកូនឲ្យកោតខ្លាចព្រះអម្ចាស់" និង ឪពុករាល់គ្នា មិនឲ្យខឹងកូនរបស់ខ្លួន ក្រែងលោបាក់ទឹកចិត្ត ។"[១៣] ដោយហេតុថាសំបុត្ររបស់លោក ប៉ូល តម្រូវឲ្យអានឮខ្លាំងៗ ដល់ក្រុមជំនុំទាំងមូល ដែលបានទទួលសំបុត្រនោះ ហេតុការណ៍ដែលគាត់បានលើកឡើងមកនិយាយនោះគឺថា ឪពុកម្តាយ និង កូនគឺមានសារៈសំខាន់មែនទែន ។ ដំបូងគាត់សន្មត់ថា កូនជារបស់សហគមន៍នៃក្រុមជំនុំ និង គិតថាគេនឹងបង្ហាញដល់ក្មេងៗ នៅពេលគេអានសំបុត្ររបស់គាត់ ។ ទីពីរ គាត់ជំរុញឲ្យមានភាពទទួលខុសត្រូវទៅវិញទៅមក ចំពោះឪពុកម្តាយ និង កូន ។ បញ្ហានេះ គឺជាការសន្និដ្ឋានរួម មួយនៅពេលនោះ ដែលថាតួនាទីរបស់ឪពុកម្តាយ មានសិទ្ធិអំណាចគ្មានព្រំដែនកំណត់ឡើយ ចំពោះកូននៅក្នុងគ្រួសារនោះ ។

---

[១២] *ចោតិយកថា(ទុតិយកថា) ៦:៤-៩ ។*

[១៣] *អេភេសូ ៦:១-៤; កូឡុស ៣:២១ ។*

ទោះបីជាយ៉ាងណាក៏ដោយ ការបីបាច់ថែទាំកូន តម្រូវឲ្យមានការលះបង់ "ចូរស្រឡាញ់អ្នកជិតខាង ដូចជាស្រឡាញ់ខ្លួនឯង" គឺជាគន្លឹះសំខាន់[១៧] ។ "ស្រឡាញ់ស្មើគ្នា និង រាប់អាន" ស្មើគ្នា ផ្តល់នូវតុល្យភាពរវាងឯកទត្តបុគ្គល បែបសម័យទំនើប សីលធម៌នៃកាតព្វកិច្ចដ៏ចម្បងតាមបែបពីបូរាណ និង ការលះបង់ផ្ទាល់ខ្លួន ។ ការយល់ដឹងពីសេចក្តីស្រឡាញ់នេះ មានសារៈសំខាន់ ជាពិសេសចំពោះម្តាយៗ និង ប្រពន្ធរាល់គ្នាជាជនជាតិខ្មែរ ដែល"ទទួលបន្ទុកនៃការធ្វើគំរូនៃសេចក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទ ដែលជាការលះបង់ផ្ទាល់ខ្លួន ដោយគ្មានតុល្យភាពត្រឹមត្រូវនោះ ។"

ចំណែកកូនៗវិញ គេអាចទទួលនូវសារៈប្រយោជន៍យ៉ាងច្រើនបំផុត ពីការចំរើនធំធាត់ចេញពីគ្រួសារ ដែលមានឪពុកម្តាយរស់នៅជាមួយនោះ ការនេះគឺមិនមែនសុទ្ធតែអាចប្រព្រឹត្តទៅបានតែទាំងអស់នោះឡើយ ។ ទាំងនៅក្នុងគម្ពីរសញ្ញាចាស់ និង ទាំងសញ្ញាថ្មី បានបញ្ជាក់ពីភាពទទួលខុសត្រូវ ចំពោះការមើលថែទាំដល់ក្មេងកំព្រាឪពុកម្តាយ និង ក្មេងកំព្រាឪពុក ។ ការក្លាយទៅជាក្មេងកំព្រាកាលពីសម័យដើម គឺមានន័យថា ទទួលនូវការបាត់បង់នូវការឧបត្ថម្ភគាំទ្រ បាត់បង់នូវភាពស្របច្បាប់ និង ក្លាយជាជនដែលងាយទទួលរងគ្រោះ ដែលតែងតែទទួលនូវការកេងប្រវ័ញ្ចពីជនដទៃ ដែលចូលចិត្តកេងយកចំណេញលើអ្នកទន់ខ្សោយ ។ យើងឃើញថា ព្រះជាម្ចាស់ជាអ្នកគាំពារដល់ក្មេង ដែលកំព្រាឪពុក[១៨] ហើយព្រះអង្គក៏ជំរុញសហគមន៍ នៃសម្ពន្ធមេត្រីឲ្យអនុវត្តការ

---

(១៧) Don Browning, "Christian Ethics and the Family Debate: An Overview," virtual *International Journal of Practical Theology*: 1999 [www2.uchicago.edu/divinity/family/].

(១៨) *ចោតិយកថា(ទុតិយកថា) ១០:១៨ ។*

អាណិតមេត្តាករុណា ស្រដៀងគ្នានេះដែរ[១៦] ។ ពិតប្រាកដដូចគ្នានេះដែរចំពោះក្រុមជំនុំ សម័យដើមដំបូង គឺជាសាសនាដែល "បរិសុទ្ធស្អាត និងឥតមានកំហុសឡើយ" គឺពួកអស់អ្នក ដែល "មើលថែទាំក្មេងកំព្រា និងស្ត្រីមេម៉ាយ បានបង្ហាញជាគំរូល្អដល់សង្គម"[១៧] ។

ការលំបាកសម្រាប់ក្រុមជំនុំខ្មែរ គឺនៅសម័យសព្វថ្ងៃនេះ មិនសូវមានគ្រួសារខ្មែរ ដែលមានកូនរស់នៅជុំគ្នាជាមួយឪពុកម្តាយទាំងពីរនាក់នោះឡើយ ។ កុមារអាចទទួលរងនូវការនិរាសព្រាត់ប្រាស់ចាកឆ្ងាយពីឪពុក ឬម្តាយ ឬក៏ត្រូវព្រាត់ទាំងឪពុកនិងម្តាយដោយសារសង្គ្រាម គ្រោះមហន្តរាយ គ្រោះថ្នាក់ ឬដោយព្រោះជម្ងឺរបស់ឪពុកម្តាយ ។ ឧទាហរណ៍កាលពីសម័យដើម គឺមានរបៀបដ៏ត្រឹមត្រូវតាមទំនៀមទម្លាប់ ក្នុងការរើសយកក្មេងកំព្រាមកបញ្ចូលនៅក្នុងគ្រួសារ ឬដាក់ឲ្យនៅក្នុងអាស្រមនៃអារ៉ាមសាសនាណាមួយ ។ ទោះបីជាយ៉ាងណាក៏ដោយសហគមន៍ខ្លះឧទាហរណ៍ដូចអស់អ្នកទាំងឡាយណា ដែលទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរដោយសង្គ្រាម ឬ ដោយឧប្បត្តិហេតុធ្ងន់ធ្ងរនៃជម្ងឺអេដស៍ គឺមានន័យថាប្រហែលជាគេមិនអាចដោះស្រាយរួចឡើយ ។ នៅក្នុងស្ថានការណ៍ទាំងនេះ បរិយាកាសនៃការគាំទ្រពីគ្រួសារ ក្រុមជំនុំអាចផ្តល់ជាគំរូមួយដែលប្លែកពីសហគមន៍ ដែលនៅជុំវិញ និងផ្តល់ឲ្យនូវការស្វែងរកមធ្យោបាយនៃការដែលអាចជួយគាំទ្រដល់ពួកក្មេងកំព្រាទាំងនោះ ។

ក្នុងក្រុមជំនុំខ្មែរមានគ្រួសារជាច្រើន ដែលមានស្ត្រីជាមេគ្រួសារ ។ គ្រូគង្វាលត្រូវតែយល់ពីស្ថានការណ៍នីមួយៗ ដែលកើតឡើង ពីព្រោះបញ្ហាទាំងឡាយ ដែលក្រុមគ្រួសារបែបនោះកំពុងប្រឈមមុខគឺមានលក្ខណៈប្លែកៗពីគ្នាដោយយោងតាមកាលៈទេសៈនៃស្ថានការណ៍នោះ ។

---

[១៦] *និក្ខមនំ(សេរីភាព) ២២:២៧ ។*

[១៧] *យ៉ាកុប ១:២៧ ។*

គ្រួសារមួយអាចទទួលនូវការរងឈឺចាប់ ដោយសារមានប្រវត្តិនៃអំពើហឹង្សា និងការប្រើអំណាចវាយដំ បង្ខំធ្វើបាបរាងកាយ ចំណែកឯគ្រួសារដទៃ អាចត្រូវដោះស្រាយលើបញ្ហាភាពកំព្រានៅមេម៉ាយ ដោយសារប្តីរត់ចោលទៅរៀបការប្រពន្ធថ្មី ឬ ដោយសារប្តីមានប្រពន្ធច្រើន ។ គឺគ្មានដំណោះស្រាយណាដែលងាយស្រួលនោះឡើយ ។ ក្រុមជំនុំដំបូងត្រូវតែស្វែងរកនូវអ្វី ដែលជាសេចក្តីត្រូវការចំពោះបញ្ហាទាំងនោះ គឺដោយការបង្កើតឲ្យមានទំនាក់ទំនងដ៏សុភាពរាបសា ដោយការសួរនូវសំណួរ និងបន្ទាប់មកគឺ ត្រៀមជាស្រេចនូវការផ្តល់ការគាំទ្រដ៏សមរម្យមួយដើម្បីដោះស្រាយបញ្ហានោះ ។

ជីដូនជីតា ម្តាយមីង ម្តាយធំ ឪពុកមា និង ឪពុកធំ ដែលនៅជិតអាចជួយគាំទ្រដល់ក្មេងកំព្រាបានដែរ ។ ការនេះគួរជួយលើកទឹកចិត្តឲ្យធ្វើការគាំទ្រ ។ នៅក្នុងករណីខ្លះ ពួកគេគឺជាអ្នកផ្តល់នូវការថែទាំយ៉ាងសំខាន់សម្រាប់កុមារ ។ ឥទ្ធិពលពីការសេពគប់មិត្តភក្តិ ក៏មានសារៈសំខាន់សម្រាប់ការលូតលាស់ផ្នែករាងកាយ ផ្នែកមនោសញ្ចេតនា និងផ្នែកវិញ្ញាណរបស់កូនក្មេងនោះឯងផងដែរ ។

ក្រុមជំនុំខ្មែរត្រូវតែព្រមទទួលស្គាល់ថា ចំនួននៃក្មេងកំព្រាហាក់បីដូចជាកើនឡើងដោយព្រោះតែជម្ងឺអេដស៍ និងក្រុមជំនុំត្រូវគិតពិចារណាពីបញ្ហាក្មេងកំព្រានេះដោយយកចិត្តទុកដាក់ជាទីបំផុត ។ ក្រុមជំនុំមួយនៅឯតាខ្មៅ ដែលមានសមាជិកនៃក្រុមជំនុំចំនួន៨០ នាក់ បានទទួលខុសត្រូវមើលថែទាំកុមារចំនួន១៧នាក់ ។ សមាជិកនៃក្រុមជំនុំខ្លះព្រមបើកទ្វារផ្ទះរបស់ខ្លួន ដើម្បីទទួលឲ្យកុមារកំព្រាឲ្យសំរាកនៅពេលយប់ ហើយបន្ទាប់មក ប្រាក់តង្វាយដែលប្រមូលបាននៅថ្ងៃអាទិត្យ ត្រូវបែងចែកមួយផ្នែកដើម្បីយកទៅទិញអាហារសម្រាប់ផ្គត់ផ្គង់ដល់កុមារទាំងនោះ ។ ក្រុមជំនុំគឺបានយកគំរូនៃការថែទាំស្ត្រីមេម៉ាយ និង ក្មេងកំព្រានៅក្នុងព្រះគម្ពីរមកអនុវត្តផ្ទាល់តែម្តង ។

មិនគ្រាន់តែពិចារណាមើល ពីលទ្ធភាពក្នុងការជួយមើលថែទាំកុមារកំព្រា នៅក្នុងសហគមន៍ប៉ុណ្ណោះទេ ក្រុមជំនុំត្រូវសម្លឹងរកមើលនូវរបៀប ដែលអាចការពារក្មេងៗនោះ កុំឲ្យកំព្រាឲ្យបានក្នុងជំហានដំបូង ។ នៅក្នុងប្រទេសកម្ពុជា ក្នុងករណីនេះអាចបណ្តាលមកពីឪពុកម្តាយស្លាប់ចោល ឬដោយសារការបោះបង់កូនចោល ប៉ុន្តែក៏មានក្មេងៗ ដែលអាចទទួលបាន ការថែទាំមិនគ្រប់គ្រាន់ព្រោះហេតុផលផ្សេងៗទៀតផងដែរ ។ ដោយសារតែ ជីវិតអាពាហ៍ពិពាហ៍កំពុងតែស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ក្រុមជំនុំត្រូវជួយគាំទ្រ និង ពង្រឹងលើផ្នែកជីវិតអាពាហ៍ពិពាហ៍នេះ ។ ការងារនេះ អាចនឹងជួយឲ្យទំនាក់ទំនងក្នុងគ្រួសារបានប្រសើរឡើងវិញ និង ការពារគ្រួសារពីការបាក់បែកគ្នា ការពារអំពើហឹង្សាលើស្ត្រីភេទ ការរត់ចោលប្រពន្ធ និង ការលះលែងគ្នា ។ ស្រដៀងគ្នានេះដែរ នៅពេលដែលទំនាក់ទំនងរវាងឪពុកម្តាយ និង កូន មានភាពល្អក់កករនោះ ការគាំទ្រពីឪពុកម្តាយ នៅក្នុងសហគមន៍មួយ ដែលប្រកបទៅដោយសេចក្តីស្រឡាញ់នោះអាចជួយការពារកូន ពីការប្រើអំពើហឹង្សា បន្តទៅជំនាន់ក្រោយទៀត ។ គឺអាចមានវិធីដទៃផ្សេងទៀត ដែលក្រុមជំនុំអាចជួយថែរក្សាកុមារ រហូតដល់ឪពុកម្តាយ ដែលកំពុងស្ថិតនៅក្នុងស្ថានភាពយ៉ាប់យ៉ឺននោះអាចស្តារស្ថានការណ៍នោះឡើងវិញបាន ។

ក្រុមជំនុំនៅក្នុងប្រទេសកម្ពុជា អាចផ្តល់ជាគំរូដ៏ល្អមួយ ដែលប្លែកគ្នាស្រឡះពីសហគមន៍ ដែលនៅជុំវិញខ្លួនយើងនោះ គឺមានន័យថា គ្រួសារគ្រីស្ទបរិស័ទចេះចុះចូលគ្នា និង មើលថែទាំកូនរបស់ខ្លួនឲ្យបានល្អ និង ទុកចិត្តលើសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលធ្វើឲ្យគ្រួសារនោះព្រមស្ម័គ្រចិត្តក្នុងការឈោងចាប់សហគមន៍ ដែលគ្មានសេចក្តីស្រឡាញ់ ហើយព្រមទទួលយកគេមកធ្វើជាគ្រួសាររបស់ខ្លួនដែរ ។